# IINeoC Project Conducted Safe Delivery App and E-learning Workshops at Regional Training Centers



*Picture: Activities of the SDA and NMCHC e-Learning Platform Workshops at RTCs.*

The Project for Improving Continuum of Care with Focus on Intrapartum and Neonatal Care (JICA-IINeoC) conducted a Safe Delivery App and E-Learning material workshop at Kampot Regional Training Center on February 18.

This completed a series of workshops previously held at the regional training centers in Kampong Cham on January 20, in Battambang on February 9, and in Stung Treng on February 10. They were all well received as participants got enthusiastically involved in the learning tasks presented at each of these venues. The Safe Delivery App was immediately downloaded so that they could start using it during the workshop. Some of the participants had already completed all of the Mylearning sections and received a certificate of completion.

It appeared that the young healthcare professionals were quite familiar with using IT tools, and that there were hardly any barriers to learning from the digital materials. Importantly the participants seemed to be having fun learning through the Safe Delivery App as it includes game-based content, and they could see their progress visually. For example, they are awarded a ☆ if they pass each section of the My Learning test.

The Safe Delivery App support group is now actively working with more than 600 registered individuals. It was noted that at the beginning of the workshops, the interaction mainly involved IINeoC staff responding to each of the questions raised, but then later the participants were helping each other to use the app effectively.

The Safe Delivery App is freely available on Google Play and in App Store:

Google Play for Android:

https://apps.apple.com/dk/app/safe-delivery/id985603707

App store for iPhone:

https://play.google.com/store/apps/details?id=dk.maternity.safedelivery&hl=en&gl=US

Access the Khmer version from; Settings >> Version >> Cambodia

# គម្រោង JICA IINeoC បានបើកសិក្ខាសាលាណែនាំអំពីកម្មវិធីការសម្រាលកូនប្រកបដោយសុវត្ថិភាព និងការរៀនតាមរយៈអេឡិចត្រូនិករបស់មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារកនៅសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពត



*រូបភាព :សិក្ខាកាមបានទាញយកកម្មវិធីការសម្រាលកូនប្រកបដោយសុវត្ថិភាពសម្រាប់វគ្គបណ្តុះបណ្តាលក្នុងសិក្ខាសាលានេះ*

*Picture: A participant downloads the Safe Delivery App for the training session.*

គម្រោងលើកកម្ពស់ការថែទាំបន្តនៅកម្ពុជា ផ្តោតលើការថែទាំស្ត្រី និងទារក ក្នុងពេលសម្រាល និងក្រោយពេលសម្រាល ( IINeoC project) បានបើកសិក្ខាសាលាណែនាំអំពី កម្មវិធីលើទូរស័ព្ទដៃ ការសម្រាលកូនប្រកបដោយសុវត្ថិភាព និងសម្ភារសិក្សាតាមរយៈអេឡិចត្រូនិករបស់មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក នៅសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពត នាថ្ងៃទី ១៨ ខែកុម្ភៈ។

នេះគឺជាសិក្ខាសាលាចុងក្រោយ បន្ទាប់ពីគម្រោងបានចាប់ផ្តើមបើកសិក្ខាសាលានេះនៅឯសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ កំពង់ចាម ថ្ងៃទី ២០ ខែមករា បាត់ដំបង ថ្ងៃទី ៩ ខែកុម្ភៈ និង ស្ទឹងត្រែង ថ្ងៃទី ១០ ខែកុម្ភៈ។ សិក្ខាកាមទាំងអស់បានសំដែងការពេញចិត្តនឹងសម្ភារៈទាំងនេះ ហើយពួកគេបានចូលរួមយ៉ាងសកម្មក្នុងការសិក្សា។ សិក្ខាកាមមួយចំនួនបានទាញយកកម្មវិធីការសម្រាលកូនប្រកបដោយសុវត្ថិភាពភ្លាមៗ ហើយចាប់ផ្តើមប្រើប្រាស់កម្មវិធីនេះនៅនឹងកន្លែងផ្ទាល់តែម្តង។ ក្នុងនោះក៏មានសិក្ខាកាមខ្លះបានបញ្ចប់ផ្នែក ការរៀនរបស់ខ្ញុំ ហើយទទួលបាន វិញ្ញាបនបត្រពីកម្មវិធីរួចមកហើយផងដែរ។

អ្នកថែទាំសុខភាពក្មេងៗភាគច្រើនហាក់ដូចជាមានភាពស្ទាត់ជំនាញក្នុងការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក ហើយពួកគេក៏ដូចជាពុំបានជួបឧបសគ្គអ្វីច្រើនតាមរយៈការរៀនពីសម្ភារៈអេឡិចត្រូនិកទាំងនេះឡើយ។ សិក្ខាកាមទាំងអស់ក៏បានបង្ហាញភាពរីករាយក្នុងការរៀនតាមកម្មវិធីការសម្រាលកូនប្រកបដោយសុវត្ថិភាពនេះ ដោយសារតែកម្មវិធីនេះបានរួមបញ្ចូលខ្លឹមសារជាលក្ខណៈហ្គេមឆ្លើយសំណួរ ហើយពួកគេអាចពិនិត្យមើលវឌ្ឍនភាពរៀងៗខ្លួនបានយ៉ាងងាយស្រួល។ ឧទាហរណ៍ អ្នកប្រើប្រាស់នឹងទទួលបាន ផ្កាយ ☆ ប្រសិនបើពួកគេបានបញ្ចប់ការប្រឡងនៅក្នុងផ្នែក ការរៀនរបស់ខ្ញុំ។ ក្រុមតេឡេក្រាមរបស់កម្មវិធីការសម្រាលកូនប្រកបដោយសុវត្ថិភាព ( Safe Delivery App - info ) មានអ្នកចូលរួមច្រើនជាង ៦០០ នាក់។ មុនពេលបើកសិក្ខាសាលានេះ ការឆ្លើយសំណួរទាក់ទងនឹងកម្មវិធីនេះ បុគ្គលិករបស់គម្រោង IINeoC ជាអ្នករាប់រង ប៉ុន្តែពេលនេះសមាជិកក្នុងក្រុមបានចាប់ផ្តើមជួយគ្នាទៅវិញទៅមកដើម្បីប្រើប្រាស់កម្មវិធីនេះប្រកបដោយប្រសិទ្ធភាព។

កម្មវិធីការសម្រាលកូនដោយសុវត្ថិភាពអាចទាញយកប្រើប្រាស់ដោយឥតគិតថ្លៃតាមរយៈ Google Play និង App Store:

Google Play for Android:

https://apps.apple.com/dk/app/safe-delivery/id985603707

App store for iPhone:

https://play.google.com/store/apps/details?id=dk.maternity.safedelivery&hl=en&gl=US

Access the Khmer version from; Settings >> Version >> Cambodia